**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងសាជាថ្មីដល់បងប្អូនអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដែលកំពុងធ្វើការតវ៉ាដោយលើកមូលហេតុថា និយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដល់ខ្លួនមិនត្រឹមត្រូវតាមច្បាប់ សូមអញ្ជើញមកក្រសួងចាប់ពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២២ តទៅ នៅរៀងរាល់ម៉ោងធ្វើការ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៨៧២ ១៦១/០៩២ ៨៨៨ ៥៨៥/០៨៧ ៥២៥ ៦៥៦ ដោយផ្តល់នូវព័ត៌មានអំពីប្រាក់ឈ្នួល, ប្រាក់អត្ថប្រយោជន៍ដែលខ្លួនធ្លាប់ទទួលបាន, រូបមន្តគណនា និងមូលដ្ឋានគណនាដែលខ្លួនចង់បាន ដើម្បីក្រសួងធ្វើការផ្ទៀងផ្ទាត់ឡើងវិញ។ ក្រសួងនឹងបង្គាប់ឱ្យនិយោជកធ្វើការទូទាត់សំណងបន្ថែមដល់បងប្អូន ក្នុងករណីដែលក្រសួងទទួលបានព័ត៌មានពេញលេញ ហើយរកឃើញថាមានភាពលម្អៀងក្នុងការគណនាពិតប្រាកដមែន។

ក្រសួងក៏សូមធ្វើការអំពាវនាវដល់បងប្អូនដែលកំពុងធ្វើការតវ៉ាទាំងអស់ វិលមកអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីនៃការដោះស្រាយវិវាទការងាររួមវិញ ស្របតាមស្មារតីមាត្រា៣០២ ដល់មាត្រា៣១៧ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ៣១៧សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ដែលបានកំណត់នីតិវិធីបន្ត គឺត្រូវប្តឹងទៅតុលាការដើម្បីបញ្ចប់ករណីវិវាទ ក្រោយពេលការផ្សះផ្សា ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការអនុវត្តវិធានការវិវាទ ត្រូវបានតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ៥២៤ "ត" ដ.រ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយបានកំណត់គុណវុឌ្ឍិថា ជាកូដកម្មខុសច្បាប់ និងត្រូវចាត់ទុកថាជាកំហុសធ្ងន់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អតីតបុគ្គលិកដែលកំពុងធ្វើការតវ៉ា និយោជក និងសាធារណជនជ្រាបជាព័ត៌មាន។

*ថ្ងៃអាទិត្យ ១៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២២*